# ធម៌សម្រាប់សូត្របុណ្យបច្ច័យបួន
# និងពាក្យខមាទោសមាតាបិតា

ថ្ងៃនេះជាថ្ងៃឧឡារិក ពិធីអធិកអធម្មក្រៃ
កូនបានធ្វើបុណ្យយ៉ាងប្រពៃ ជូនព្រះមេថ្លៃអ្នកមានគុណ ។
ពុកអើយម៉ែអើយកូនសូមទោស បើមានខាតខុសបទត្រង់ណា
ចំពោះមាតានិងបិតា ដោយកាយវាចាចិត្តឆ្គាំឆ្គង ។
កាលកូននៅក្នុងវ័យតូចស្ទើរ ក្រែងលោមានធ្វើខុសកន្លង
ពោលពាក្យតូចធំផងរំលង ទៅលើអ្នកសងដែលមានគុណ ។
មានពាក្យទ្រគោះទាស់ប្រកែក ជជែកជជេសលើសស័យស៊ុន
ដោយចិត្តអន្ធពាលក្នុងកាលមុន កូនសូមបន្ទន់កាយវាចា ។
សូមលើកអញ្ជលីផ្គងប្រណម្យ ក្រួញក្រាបបង្គំទៀបបាទា
កូនសូមសច្ចានិងស្មាលា ទោសទាស់នានានោះទាំងអស់ ។
តាំងពីព្រះមេមានគុណធ្ងន់ អត់ធន់ថ្នមកូនទ្រាំពពោះ
បីបាច់រក្សាពុំមានមោះ ដោយចិត្តអនុគ្រោះបុត្រក្នុងផ្ទៃ ។
ដំណើរដំណេកផ្ទេកបរិភោគ អធ្យោគខុសខាតអធ្យាស្រ័យ
ទោះស្រេកទោះឃ្លានញ័រល្វិតល្វៃ ច្រើនខែច្រើនថ្ងៃទើបឆ្លងផុត ។
លោកអើយកូនសូមស្មារលាទោស បើកូនមានខុសដោយវាចា
ឬបើមានដោយចេតនា សូមលោកមេត្តាត្រាប្រណី ។

# ធម៌រំលឹកគុណមាតាបិតា

បពិត្រមាតានិងបិតា កូននឹកខ្លោចផ្សាពេកអំបាយ
តាំងពីកូនកើតមានរាងកាយ អ្នកតែងខ្វល់ខ្វាយថែរក្សា ។
ឱ! អ្នកម្ចាស់ថ្លៃវិសេសលន់ អ្នករងទុក្ខធ្ងន់ពេកណាស់
ណាព្រោះអ្នកខំថ្នមថែរក្សា មិនអាចពណ៌នាឱ្យអស់បាន ។
ហេតុនេះកូនសូមផ្គងអញ្ជលី លើកហត្ថទាំងពីរ
បង្គំបាទាព្រះក្បែមក្សាន្ត ទោសខុសប៉ុន្មានសូមប្រណី ។
ម្ចាស់អើយកាលកូនទ្រហោយំ អ្នកស្ទុះបង្គំត្រកងបី
ច្រៀងបំពេកូនដោយប្រិមប្រិយ៍ ដោយពាក្យមេត្រីផ្អែកកូនណា ។
ទឹកម្ដូត្រទឹកមាត់លាមកផង និងគ្រឿងសៅហ្មងផងនានា
អ្នកកាន់អ្នកចាប់ស្រវាលាង ដោយហត្ថាផងមិនជិនឆ្អន់ ។
បពិត្រអ្នកម្ដាយមានករុណា បិតាមានគុណវិសេសលន់
កូនសូមគោរពព្រះគុណធ្ងន់ សូមអ្នកសោភ័ណបានសុខហោង ។

# កូនសូមខមាទោសមាតាបិតា

គ្រានេះកូនសូមខមាទោស កូនបានជាខុសនឹងមាតា
ក្រែងបានប្រមាថដោយវាចា សូមអត់ទោសាណាលោកម្តាយ ។
ពេលនេះកូនសូមថ្វាយបង្គំ ម្រាមដៃក្រពុំទាំងពីរកាយ
ក្រាបក្រោមបាទាណាលោកម្តាយ អត់ទោសទាំងឡាយឱ្យកូនផង ។
ទោសមួយកូនតាំងនៅក្នុងផ្ទៃ ធ្វើទុក្ខពុំរែរដល់មាតា
ដើរឈប់អង្គុយគ្រប់វេលា បរិភោគអាហារលំបាកក្រៃ ។
អាហារហិរប្រៃក្តៅត្រជាក់ មិនមានឱ្យកូននៅក្នុងផ្ទៃ
ទោះក្រែងពិសារយ៉ាងណាក្តី ខំអធ្យាស្រ័យការស្រេកឃ្លាន ។
ទុក្ខព្រួយយ៉ាងនេះអស់ដប់ខែ ពុំដែលមានល្ហែពេលណាបាន
សុខស្រួលសប្បាយកាយក្សេមក្សាន្ត ទុក្ខជោគជាំប្រាណគ្រប់វេលា ។
ដ៏រាបមកដល់សព្វថ្ងៃនេះ លោកម្តាយមិនចេះអស់មេត្តា
នៅតែពោរពេញដល់បុត្រា លំបាកកាយាលុះឥឡូវ ។
ពេលនេះកូនសូមជូនកុសល ដែលកូនតម្កល់ បុណ្យទាំងឡាយ
ធម្មទានយប់ថ្ងៃនេះយ៉ាងក្បោះក្បាយ សូមទានលោកម្តាយទទួលយក ។
កូនសូមឧទ្ទិសចំណែកផល ជូនដល់មាតានិងបិតា
ឱ្យបានសម្បត្តិបីប្រការ រួចពីទុក្ខាសព្វៗកាល ។
យើងខ្ញុំអ្នកតែងថ្លែងអរគុណ សូមបុណជួយបាំងបាបឱ្យបាត់
វេរាទាំងប្រាំឱ្យខ្ចាយខ្ចាត់ សូមលុះអរហត្តដូចបំណង ។

## កូនសូមខមាទោស

កូនសូមឱនកាយ ថ្វាយវន្ទា បង្គំសូមខមាទោសផ្សេងៗ
ដែលកូនខុសហើយ តាំងពីក្មេង កាយចិត្តវង្វេង និងវាចា ។
សម្ដីធ្ងន់ស្រាលកូន ពុំបានដឹង តបតមាតាំរឹង តែងឆ្លើយឆ្លង
ឯកាយទៀតសោត ក៏កន្លង ឆ្គាំឆ្គងពុំសម អធ្យាស្រ័យ ។
រីឯចិត្តនោះក៏របឹង ចចេសទទឹងមិនព្រមតាម
កូនខុសច្រើនណាស់នឹងបំរាម ដែលលោកបានហាមប្រៀនប្រដៅ ។
ព្រោះកូនពេលនោះ ជាមនុស្សល្ងង់ ចិត្តពាលទាំងស្រុង គ្មានបានយល់
មិនស្គាល់គុណទោស ចិត្តមោះមល់ មិនបានដឹងយល់ហេតុចំរើន ។
ទើបតែពេលនេះ កូនស្វាងចៃស កូនបានដឹងរិះការរាក់ជ្រៅ
ដឹងស្គាល់គុណទោស លោកម៉ែឪ គោរពតទៅ អង្វែងណា ។
បពិត្រព្រះមេរុ មានគុណធ្ងន់ សូមលោកអត់ធន់ ដល់កូនណា
អនុគ្រោះអនុញ្ញាត នូវទោសា ដល់កូនគ្រប់គ្នា ដោយសន្ដោស ។

## ជូនខោអាវទី១

១.	កូនប្រុសកូនស្រី ថ្វាយបង្គំលើកហត្ថប្រណម្យ ក្រាបវន្ទា
លើកខោលើកអាវ ផងនានា ជូនដល់បុព្វា អ្នកមានគុណ ។

២.	សូមលោកមាតានិងបិតា ទទួលជ្រះថ្លាដោយគោរព
ចិត្តកូនតបគុណដោយត្រង់ស្មោះ ចំពោះទៅលើអ្នកមានគុណ ។

៣.	សូមលោកអភ័យនូវទោសា ខន្តីខមាដោយអភិយោ
តាំងពីកូនបានមកនៅជ្រក ក្រោមម្លប់បុណ្យលោកវេលាណា ។

៤. រហូតដល់ធំចំរើនវ័យ មានប្រពន្ធប្តីក្រុមគ្រួសារ
ដោយលោកសន្តោសកូនប្រុសស្រី មានព្រហ្មវិហារមកលើកូន ។

៥. ហេតុនេះក្រែងកូន ប្រព្រឹត្តខុសនាំមកជាទោស
ឱ្យសាបសូន្យក្រែងធ្លាក់មកលើ ដល់រូបកូនដោយគ្មានចេតនា
ទេមាសថ្លៃ ។

## ស្រង់ទឹកទី២

១- បពិត្រមាតានិងបិតា កូនលើកហត្ថជម្រះកាយ
ជូនលោកឪពុកនិងអ្នកម្តាយ ដោយចិត្តរីករាយពន់ពេកណាស់ ។

២- សុគន្ធវារីមានក្លិនក្រអូប ដែលកូនលើកមកជម្រះកាយ
បំបាត់អសោចិ៍ មន្ទិលព្រះលើកហត្ថ សំពះឡើងបីដង ។

៣- វិបាកកម្មដែលកូនមាន បានធ្វើបំពានមានប្រាកដ
ដោយបុញ្ញកម្មនេះតាមបទ កូនសូមសន្ធត់ស្មាលាទោស ។

៤- ភោតោទេវសង្ឃាយោ ទេវតាចុះមកជុំត្រៀបត្រា
ប្រកាសអញ្ជើញអស់ទេវតា មានព្រះឥន្ទ្រាជាប្រធានហោង ។

(ចប់ស្រង់ទឹកទី២)

## ជូនគ្រែស្បង់ទី៣

១. ពេលនេះកូនសូមថ្វាយបង្គំ លើកហត្ថប្រណម្យក្រាបវន្ទា
លើកត្រ័យស្បង់ផងគ្រប់នានា វន្ទាលើកជូនលោកមានគុណ ។

២. សូមព្រះមាតានឹងបិតា រីករាយជ្រះថ្លាក្នុងហឫទ័យ
កូនសូមតបគុណព្រះម្ចាស់ថ្លៃ គុណហួសនិស្ស័យឥតឧបមា ។

៣. ទើបមាននាមថាបុព្វាចារ្យ ឱ្យកូនសិក្សាគ្រប់វិស័យ

មុនគ្រូទាំងពួងផ្គងដឹកដៃ ឱ្យដឹងតាមន័យវ័យកុមារ ។

៤. កូនបានមានរូបមានសិរី ដោយគុណម្ចាស់ថ្លៃ
ថ្លាប្រណិតប្រណីសង្គ្រោះ ចំពោះពិតក៏រិតមេត្តា
ករុណាធ្ងន់ ។

៥. ពេលនេះកូនសូមជូនកុសល ដកល់ចំពោះលោកមានគុណ
ចំណាយធនធានចាត់ចែងបុណ្យ សូមលោកមានគុណទទួលហោង ។

(ចប់ជូនត្រៃស្បង់)

## ពេលព្រឹកជូនបាយ

១. ខ្ញុំកូនប្រុសស្រី សូមថ្វាយបង្គំ លើកហត្ថប្រណម្យក្រាបវន្ទា
ចំពោះមាតានិងបិតា សូមលោកជ្រះថ្លាកុសលនេះ ។

២. ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្ស ពិធីអធឹកអធម្មណាស់
កូនប្រុសកូនស្រីទាំងក្មេងចាស់ ចិត្តជ្រះស្រឡះក្នុងកុសល ។

៣. មូលមិត្តគ្នាជាឯកឆ័ន្ទ ចិត្តយ៉ាងសំខាន់កតញ្ញូតា
បូជាទ្រព្យធនផងនានា ដល់លោកមាតានិងបិតា ។

៤. ដូចនេះសូមលោកទទួលយក នៅគ្រឿងឧប្បភោគបរិភោគ
បង្អែមចំណីម្ហូបអាហារ នឹងគ្រឿងបរិក្ខារណាលោកអើយ ។

៥. សូមលោកទទួលដោយសោមនស្ស ចិត្តកូនត្រង់ស្មោះចំពោះហើយ
បូជាទាំងអស់គ្មានស្តាយក្រោយ ជូនលោកឱ្យហើយទាន់ភ្នែកឃើញ ។

(ចប់ពេលជូនបាយសម្ល)

## ជូនសំលៀកបំពាក់ពេលស្រង់ទឹករួច

១. រួចហើយកូនប្រុសនឹងកូនស្រី សូមលើករបស់ថ្មីផ្លាស់ជូនលោក
សំពត់ខោអាវកូនលើកមក តាក់តែងជូនលោកអ្នកមានគុណ ។

២. មានទាំងកន្សែងថ្មីបារីម្លូរស្លា ដៃកូនទាំងគូរលើកជូនដាក់

សូមលោកទទួលដោយស្មោះស្ម័គ្រ ខ្ញុំសូមបញ្ជាក់បុណ្យខែភ្លឺ ។

៣, បុណ្យនេះឃើញជាក់ឥតសង្ស័យ កូនប្រុសកូនស្រីជុំត្រៀបត្រា
សាងកល្យាណកម្មច្បាស់នេត្រា មាតាបិតាទទួលពិត ។

៤, ប្រោសព្រហ្មរួចស្រេចកូនសូមហែរ នៅអង្គព្រះមេទាំងពីរប្រាណ
លើកម្រាលថ្មីយ៉ាងសំសាន្ត ចូលរោងបុណ្យបានកូនតបគុណ ។

៥, កូនប្រុសបើកខ្លោះបាំង ថ្វាយព្រះ កូនស្រីសំពះឈរអមជិត
ជូនដំណើរលោកមានគុណពិត ចិត្តកូនរិះគិតរំភើបក្រៃ ។

៦, ប្រដាប់ប្រដាទាំងប៉ុន្មាន រូបកូនគ្រប់ប្រាណបានគិតឆ្នៃ
ជូនលោកមានគុណតាមប្រពៃ សូមអធ្យាស្រ័យទទួលយក ។

៧, ព្រមទាំងកុសលមានផ្សេងៗ រូបកូនពីក្មេងសន្សំទុក
ទានសីលភាវនាជាប្រមុខ លើជូនលោកឪពុកនឹងអ្នកម្តាយ ។

៨, សូមលោកទទួលដោយអនុគ្រោះ ផលបុណ្យទាំងនោះល្អឆើតឆាយ
ជូនដំណើរលោកផុតចតុរាបាយ សូមសុខពណ្ណរាយរហូតហោង ។

(ចប់ជូនសំលៀកបំពាក់)

## ជូនត្រៃដល់អ្នកមានគុណ

១, កូនសូមលើកត្រៃគ្រឿងចីវរ កូនលើកដៃទ្រជូនចំពោះ
នូវគ្រឿងបរិក្ខាសព្វទាំងអស់ រូបកូនស្ម័គ្រស្មោះសូមលើកថ្វាយ ។

២, ឥឡូវថ្ងៃនេះកូនឱនកាយ គោរពក្រាបថ្វាយដោយពេញចិត្ត
បងប្អូនទាំងឡាយមកជុំជិត គឺកកងសន្ធឹកសែនរីករាយ ។

៣, សូមលោកទាំងពីរទទួលយក ដែលកូននាំយកមកថ្វាយហើយ
មិនមានខ្វះអ្វីៗសោះឡើយ អ្នកមានគុណអើយទទួលយក ។

៤, គ្រឿងចីវរល្អដ៏ប្រពៃ កូនបានលក់លៃនាំគ្នាធ្វើ
ជូនលោកទាំងពីរសព្វសារពើ កូននាំគ្នាធ្វើជូនលោកទាំងពីរ ។

៥, សូមលោកទាំងពីរអនុមោទនា ដែលកូនសទ្ធាចំពោះត្រង់
ចិត្តលោកទាំងពីរសូមខំផ្ចង់ ផ្តោតចិត្តដំរង់អនុមោទនា ។

(ចប់ជូនត្រៃដល់មាតាបិតា)

## សូមខមាទោសមាតាបិតា

១, ព្រះមេមានគុណ លំបាកពេកពន់ ថែរក្សាកូនពរពោះដប់ខែ
ស្មើរតែនិងសូន្យ រហូតដល់កូនសម្រាលចាកផ្ទៃ ។

២, បំបៅថ្មមបុត្រ លាមកម៉ូត្រសុទ្ធជុះលាងរាល់ថ្ងៃ
រហូតកូនធំបានចំរើនវ៍យ អប់រំបុត្រថ្លៃសព្វមុខវិជ្ជា ។

៣, ចាត់ចែងទុកដាក់ ចែកកេ្តីមតិក រៀបចំគ្រួសារ
កូនចាំក្នុងចិត្ត អាណិតមាតា នឹងគុណបិតា ថ្លឹងថ្លែងពុំបាន ។

៤, ថ្ងៃនេះជាថ្ងៃ ដ៏ឧត្តមក្រៃ កូនបានរៀបចំ
ធ្វើបុណ្យថ្វាយភ័ត្ត ចំពោះព្រះសង្ឃ សូមពុកម៉ែបាន សុខផុតលោកា ។

៥, ភោជភ័ត្តបរិសុទ្ធកូនសូមលំអុត លុតលើកហត្ថជូនលោកមានគុណ
ដ៏ធ្ងន់អស្ចារ្យ កូនសូមស្មាលាទោសព្រះកន្លង ។

៦, អ្នកម្តាយជាទុក្ខពុំដែលស្រណុក ដល់តិចឡើយហោង
តែងនឹងជាទុក្ខពុំសុខជាម្តង ត្បិតខ្ញុំនេះហោង ជាទុក្ខមហិមា ។

៧, ឯព្រះមាតា អ្នកឈឺខ្លោចផ្សារ ត្បិតខ្ញុំនេះនៃ
អ្នកដេកអាំងភ្លើង អស់ប្រាំពីរថ្ងៃ ទើបស្រាលជើងដៃ
បរិបូរណ៍ហើយហោង ។

៨, ខ្ញុំលាទោសមួយ ត្បិតអ្នកម្តាយព្រួយ ចិញ្ចឹមរ៉ាប់រង
ទុក្ខភ័យប៉ុន្មានមិនឱ្យមានហ្មង អ្នកតែងរ៉ាប់រង ទុក្ខធ្ងន់ពេកណា ។

៩, ខ្ញុំលាបាបមួយត្បិតអ្នកម្តាយព្រួយ ពិបាកច្រើនគ្រា ដេកនឹងលាមក
នឹងនោមកាលជា ក្មេងឡើយខ្ញុំលា អ្នកម្តាយរក្សា ។

១០, កូនសូមស្មាលាក្រែងមានវេរវាអំពើរទាំងឡាយកាលលោកដេកលក់
បានសុខសប្បាយក្រែងខ្ញុំមាក់ងាយ យំឱ្យលោកភ្ញាក់ ។

១១ ,លាទោសគិតក្រែង បាបកម្មនោះឯង ធ្វើឱ្យលោកអាក់
រីឯខ្ញុំនេះយំហើយទរធាក់ បាបនោះអប្បលក្ខ័ ខ្ញុំសូមស្មាលា ។

១២ ,ក្រែងខ្ញុំទ្រគោះ មាត់រឹងប្រឈ្លោះមាតាបិតា
ក្រែងមានប្រមាថ ច្រើនជាតិក្តីណា ក្រែងខ្ញុំមុសាចាស់ទុំនោះហោង ។

## មាតាបិតាតបកូនវិញ

១, ហៃកូនពិសីមាសឪពុក ម្តាយផ្តាំកូនទុកជាតម្រា
កូនបានតបស្នងសងគុណណា មាតាបិតាថ្លៃវិសេស ។

២, កូនលើកតម្កើងនៅកិត្តិយស លើកកេរ៏លើកឈ្មោះនៅមាតា
បិតារបស់កូនយ៉ាងថ្លៃថ្លា ទាំងពីរអង្គារត្រេកអរក្រៃ ។

៣, កូនបានរៀបរាប់នូវរឿងចាស់ ម៉ែឪនឿយណាយគ្មានស្រាកស្រាន
ឥឡូវកូនប្រុសស្រីកល្យាណ បាបទន់ប្រាណថ្វាយវន្ទា ។

(ចប់មាតាបិតាតបកូនវិញ)

## បទសូត្រព្រះរស់

១, មាតាបិតាជាព្រះរស់ នឹកនៅក្នុងផ្ទះយើងរាល់គ្នា
ជាសក្ការៈរូបបូជា កូនត្រូវវន្ទារាល់យប់ថ្ងៃ ។

២, ព្រះមានគុណធ្ងន់អស្ចារ្យ លើបុត្រធីតាច្រើនក្រាសក្រៃ
មិនអាចគណនាឱ្យតម្លៃ ថាថ្លៃប៉ុណ្ណេះប៉ុណ្ណោះបាន ។

៣, លោកបានបង្កើតបុត្រធីតា បីបាច់រក្សាមិនធ្វេសខាន
ទោះនឿយកាយចិត្តទាំងប៉ុន្មាន ក៏លោកពុំមានភ្លេចពេលណា ។

៤, កូនតូចលោកថែទំណើ ដល់ធំដឹងក្តីឱ្យសិក្សា
កម្លោះក្រមុំរៀបរៀបការ រៀបបុត្រធីតាឱ្យមានគូរ ។

៥, ចែកទ្រព្យសម្បត្តិឱ្យគ្រប់មុខ ប្រាថ្នាក្តីសុខសយូរអង្វែង
ចង់បានឱ្យកូនរកស៊ីធូរ គិតគូរដាស់តឿនរាល់យប់ថ្ងៃ ។

៦, បើកូនប្រុសស្រីមានក្តីទុក្ខ ចិត្តម្តាយឪពុកតែងទោមនស្ស
បើកូនប្រុសស្រីបានថ្កើងខ្ពស់ ចិត្តលោកអរណាស់សប្បាយក្រៃ។

៧.	នេះហើយគឺព្រះក្នុងផ្ទះយើង កូនត្រូវតម្កើងរាល់យប់ថ្ងៃ
គោរពបូជាព្រះម្ចាស់ថ្លៃ ព្រះឱ្យនិស្ស័យព្រះកន្លោង ។
(ចប់បទសូត្រព្រះរស់)

## បទខមាទោស

១.	បពិត្រលោកមាតាបិតា កូនលើកហត្ថាថ្វាយបង្គំ
ក្រាបក្រោមបាទាព្រះគុណធំ បង្គំអញ្ជលីបន្ទន់កាយ ។

២.	សូមស្មាលាទោសដែលខុសឆ្គង កម្មពៀរសៅហ្មងផងទាំងឡាយ
ពាក្យធ្ងន់មាត់ស្រាល់ដោយចិត្តកាយ សូមលោកអ្នកម្តាយអត់ទោសភ័យ ។

៣.	ឱ! ម្ចាស់ថ្លៃវិសេសលន់ លោករងទុក្ខធ្ងន់ពេកណាស់ណា
ព្រោះខំបីបាច់កូនស្ងួនភ្ជា មិនអាចពណ៌នាឱ្យអស់បាន ។

៤.	ហេតុនេះកូនសូមផ្គងអញ្ជលី លើកហត្ថទាំងពីរបន្ទន់ប្រាណ
បង្គំព្រះបាទសូមក្សេមក្សាន្ត ទោសខុសប៉ុន្មានសូមប្រណី ។

៥.	ម្ចាស់អើយកាលកូនទ្រហូរយំ លោកស្ទុះម្ទីម្ទាត្រកងបី
ស្រែកច្រេងបំពេរដោយ ប្រិមប្រិយ៍ដោយពាក្យមេត្រីផ្តេកកូនណា ។

៦.	ទឹកម៉ូត្រទឹកមាត់លាមក ផង អស់គ្រឿងសៅហ្មងផងទាំងឡាយ
អ្នកចាប់កាន់លាងងូតដុះកាយ ឥតមានជិនណាយធុញទ្រាន់ឡើយ ។

៧.	បពិត្រលោកម្តាយមានករុណា បិតាមានគុណវិសេសលន់
ភ្នំព្រះសុមេរុំហៅមហាធ្ងន់ អាចយកមកថ្លឹងស្មើរពុំបាន ។

៨.	ហេតុនេះកូនសូមផ្គងអញ្ជលី លើកហត្ថទាំងពីរបន្ទន់ប្រាណ
ទានសីលកូនធ្វើទាំងប៉ុន្មាន សូមជួយជាស្ពានយានទៅមុខ ។

៩.	សូមបានសម្រេចដូចប្រាថ្នា អរហន្តរហត្តាឆ្លងទៅមុខ
និព្វានផុតឋានលែងកើតទុក្ខ សែនសុខលើសលន់ប្រសើរហោង ។
(ចប់បទខមាទោស)

## *ធម៌រលឹកគុណ*

១.	អបំនាមោសិរោរាប   ឱនកាយបន្ទាបក្រាបវន្ទា

សុំពោលសម្ដែងថ្លែងពណ៌នា វន្ទាគោរពព្រះគុណថ្លៃ ។

២, មាតាបិតាបង្កើតកាយ មានគុណជ្រៅឆ្ងាយលើសជលសៃ ធ្ងន់លើសប្រថពី ឥតឧបមេយ្យ
ខ្ពស់ផុតនិស្ស័យសុមេរា ។

៣, ពីកាលកូននៅក្នុងឧទរ មាតាថ្នមទ្រគ្រប់តិរិយា
ប្រសូត្រចេញរួចមកកាលណា មាតាប្រទានទឹកព្រះរក្សា ។

៤, បីបមថ្នមទ្របំពេរលាង បញ្ចេញសូរសៀងច្រៀងបំពេរ
បំបោសអង្អែលអស់កាយេ ព្រះមេមានគុណធ្ងន់ជ្រៅឆ្ងាយ ។

៥, បពិត្រលោកមាតាបិតា កូននឹកខ្លោចផ្សារពេកអំបាយ
តាំងពីកូនកើតបានរូបកាយ អ្នកតែងខ្វល់ខ្វាយថែរក្សា ។

៦, ឱ! អ្នកម្ចាស់ថ្លៃវិសេសលន់ អ្នករងទុក្ខធ្ងន់ខ្លាំងណាស់ណា
ព្រោះអ្នកខំបីបាច់ស្ងួនភ្ងារ មិនអាចពណ៌នាឱ្យអស់បាន ។

៧, ដូច្នេះកូនសូមផ្គងអញ្ជលី លើកហត្ថទាំងពីរបន្ទន់ប្រាណ
បង្គំបាទាសូមក្សេមក្សាន្ត ទោសខុសប៉ុន្មានសូមប្រណី ។

៨, ម្ចាស់សើយកាលកូនទ្រហូរយំ អ្នកស្ទុះមកថ្នមត្រកងបី
ច្រៀងបំពេរកូនដោយប្រិមប្រិយ៍ ដោយពាក្យមេត្រីផ្ដេកកូនភ្ងារ ។

៩, ទឹកមាត់ទឹកម៉ូត្រលាមកផង ជាគ្រឿងសៅហ្មងផងនានា
អ្នកចាប់អ្នកស្រវ៉ា លាងដោយហត្ថាឥតជិនឆ្អន់ ។

១០, បពិត្រអ្នកម្ដាយមានគុណករុណា បិតាមានគុណពិសេសលន់
កូនសូមគោរពព្រះគុណធ្ងន់ សូមព្រះសោភ័ណបានក្សេមក្សាន្ត ។

១១, ដូច្នេះកូនសូមឧទ្ទិសផល ដឹកលំចេតនាដោយក្លាហាន
សីលទានភាវនាដែលកូនបាន សាងកម្មប៉ុន្មានជូនទៅអ្នក ។

១២, សូមលោកទទួលដោយសោមនស្ស ចិត្តខ្ញុំត្រង់ស្មោះចំពោះជាក់
ដែលខ្ញុំបានពោលពាក្យសច្ចៈ សូមជូនទៅអ្នកគ្រានោះហោង ។

(ចប់ធម៌រំលឹកគុណ)

## **អញ្ជើញមាតាបិតាឡើងបុស្សបុក**

១,	ពេលនេះកូនសូមដង្ហែរព្រះ ហែរចេញពីផ្ទះកាន់បោះសំបុក
កម្រាលពិសេសកូនក្រាលទុក ជូនលោកឳពុកនឹងអ្នកម្តាយ ។
២,	សុគន្ធវារីក្លិនក្រអូប ដែលកូនលើកមកជម្រះកាយ
បំបាត់អាសោចមន្ទិលព្រះ លើកដៃសំពះដើរបីជុំ ។
៣,	រីឯបាបកម្មដែលកូនមាន បានធ្វើបំពានមានប្រាកដ
ដោយបុញ្ញកម្មនេះតាមបទ កូនសូមសន្ទត់ស្មាលាបាប ។
៤,	ភោន្តោទេវសង្ឃាយោ ទេវតាចុះមកជុំត្រៀបត្រា
ប្រកាសអញ្ជើញអស់ទេវតា មានព្រះឥន្ទ្រាជាប្រធាន ។
៥,	សូមលោកប្រទាននូវពរជ័យ មង្គលសួស្តីគ្រប់ប្រការ
កើតមានប្រាកដគ្រប់ទិវា ទាំងពីរអង្គារជាបុព្វការី ។

(ចប់)

## មហាបាលចេញបព្វជា

១,	កាលដែលមហាបាលចេញបព្វជ្ជា ចុល្លបាលកិន្និដ្ឋាសោកសង្រេង
បំរះនរនៀលយំក្តែង១ ទួញសោកសង្រេងរៀងរាប់ថា ។
២,	ឱម្ចាស់បងអើយប្អូនអាល័យ កាលបិតាក្ស័យសូន្យសង្ខារ
ទុក្ខរូបព្រះបងដូចបិតា មិនគួរយាត្រាចោលប្អូនឡើយ ។
៣,	ក្រោយទៀតមាតាក៏មរណៈ ប្អូនបានរូបនាក់បងនេះហើយ
ដូចជាមាតាទុក្ខប្អូនស្បើយ មិនគួរបួសឡើយណានាក់បង ។
៤,	សម្បត្តិយើងមានធ្វើទានទៅ រក្សាសីលនៅផ្ទះវិញបង
ចាំចាស់សឹមបួសតាមបំណង ប្អូនសូមអ្នកបងនៅជាគ្នា ។
៥,	ថាបើអ្នកបងទៅបួសហើយ ទុក្ខប្អូនពុំស្បើយព្រោះកំព្រារ

ព្រោះព្រាត់ប្រាស់បងឆ្ងាយពុំងារ ប្អូននៅកំព្រារងារណាស់ ។

៦, មហាបាលស្តាប់ហើយឆ្លើយតបថា ប្អូនអើយទេសនាព្រះជាម្ចាស់
ពីធមិត្រៃលក្ខណ៍បងឮច្បាស់ មិនមែនជាផ្ទះរក្សាបាន ។

៧, បិតាភរិយាបុត្រធនធាន ដែលខ្លួនធ្លាប់មានទាំងប៉ុន្មាន
ព្រមទាំងរាងកាយនោះគ្រប់ប្រាណ ស្លាប់ទៅមិនបានយកទៅឡើយ ។

៨, តែងតែបោះចោលក្នុងភពចាស់ ប្អូនអើយនេះច្បាស់ប្រាកដហើយ
ហេតុនេះអ្នកកុំឃាត់បងឡើយ បងនឹងបួសហើយថ្ងៃនេះហោង ។

( ចប់ )

## ផលបុណ្យយិតយោង

១, ផលបុណ្យយិតយោង យកទៅលើរុះរើទ្រព្យធនធានមានតំលៃ
យកមកប្រគាល់រាល់ខែថ្ងៃ និស្ស័យហាក់ដូចមិត្តសំឡាញ់ ។

២, ហេតុនេះអ្នកអើយកុំប្រមាថ គួរខំសង្វាត់លះកំណាញ់
កំណើតចិត្តបាបឱ្យអស់ចេញ ប្រឹងប្រែងបំពេញទានទាំងពួង ។

៣, រក្សាសីលប្រាំកម្មបទ១០ ឱ្យបានចេះចប់គ្រប់ៗកង
ទាំងសីលប្រាំបីឱ្យហ្មត់ហ្មង នឹងភាវនាផងឱ្យបានខ្លះ ។

៤, ថាបើអ្នកនាងស្រឡាញ់ខ្លួន គប្បីថែធួនចិត្តឱ្យល្អះ
កម្មណាមិនល្អខំកាត់លះ ទើបជួបប្រទះសុខថ្កើងថ្កាន ។

៥, ទានសីលភាវនាជាកំលាំង ភើចញ្ជាំងដឹកនាំខ្លួនឱ្យបាន
សោយសុខសម្បត្តិទិព្វវិមានរហូតដល់ឋាននិព្វានហោង ។ (ចប់)

## បទថ្វាយផ្កា

១,	បូទំក្រមុំរីក មានចិត្តត្រេក កាច់មកថ្វាយ ។
២,	បូទំក្រមុំចាយ បង្អាច់កាយ កបកេសរ ។
៣,	លុតលើកទាំងទស្សុករ ប្រណម្យមដាក់ លើសិរសី ។
៤,	ក្រួញក្រាប ក្រោមព្រះបាទ អភិវាទវន្ទា ។
៥,	ថ្វាត់ថ្វាយ ទៅព្រះស្រី រតនៈត្រ័យ ស្រីក្រឡា ។
៦,	រុងរឿងបល្លាំងពេជ្រ វិចិត្រស្រេច ក្បាច់រចនា ។
៧,	ថ្វាត់ថ្វាយ វន្ទា សូមបានសុខ និព្វានហោង ។

(ចប់)

## សូត្រលោកឆាន់

១,	ថាឱព្រះគុណអើយ មិនយូរឡើយព្រះទ្រង់ញាណ
	យាងចូលកាន់និព្វាន ចោលខ្ញុំអានន្ទនៅកំព្រា ។
២,	ខ្ញុំតែងធ្លាប់គោរព ទាំងថ្ងៃយប់សព្វវេលា
	ពេលស្រង់ព្រះគង្គារ អានន្ទធានាដងមកថ្វាយ ។
៣,	កន្លែងតែងសៃយ៉ាស់ ខ្ញុំបោសច្រាសសព្វៗកាល
	ពុំមានចិត្តនឿយណាយ ខ្ញុំខ្វល់ខ្វាយសព្វវេលា ។
៤,	ពេលសោយថ្នាំឱសថ ខ្ញុំតែងចាត់ថ្វាយសាស្ដា
	ពេលប្រោសព្រះសត្វា ខ្ញុំនេះណាតាមទៅផង ។
៥,	ពេលព្រឹកសោយព្រះស្ងួន ខ្ញុំអានន្ទនាំមកផ្គង
	ពីថ្ងៃនេះទៅហោង ព្រះបងចោលខ្ញុំអានន្ទហើយ ។
៦,	ពេលយាងទៅបិណ្ឌបាត្រ ខ្ញុំសង្វាតតាមភគវន្ត
	ហើយនិងពេលទ្រង់ឆាន់ ខ្ញុំអានន្ទតែងបក់ផាត់ ។
៧,	ព្រះរៀមអើយទៅទីណា ឧស្សាហ៏តាមប្រតិបត្តិ
	ឥឡូវនេះព្រះចោមក្ស័ត្រ ទ្រង់កាត់ចោលខ្ញុំអានន្ទហើយ ។

៨.　ពេលសោយព្រះស្ងែយ៉ាស់ ព្រះជាម្ចាស់សោយក្រយ៉ា
ខ្ញុំបានព្រះពុទ្ធណា ធ្វើបូជាតទៅមុខ ។
៩.　ពេលស្រង់នូវពេលផ្ទុំ ខ្ញុំអានន្ទតែងបក់ផាត់
សម្រេចព្រះអរហត្ត ភាវនាខ្ជាប់ដល់និព្វានហោង ។

(ចប់)

## ព្រះត្រៃលក្ខណ៍របស់នាងកិសាគោតមី

១.　គ្រានាងកិសាគោតមី នាងមានមេត្រីនិងបុត្រា
បីកូនទាំងស្លាប់ទៅសាស្តា សូមឱ្យមេត្តាជួយមើលកូន ។
២.　ដែលស្លាប់សូន្យហើយឱ្យរស់វិញ ទុក្ខនាងពោរពេញស្ទើរនឹងសូន្យ
បាត់បង់ជីវិតព្រោះតែកូន ឥតមានបងប្អូនណាថាបាន ។
៣.　គ្រានោះឯអង្គព្រះសាស្តា ឱ្យនាងយាត្រាសព្វភូមិស្ថាន
ស្វែងរកគ្រាប់ស្ពៃមកឱ្យបាន រកតែផ្ទះគ្មានស្លាប់សឹមយក ។
៤.　ឯនាងកិសាគោតមី លើកកូនឡើងបីទៅស្វែងរក
មិនបានគ្រាប់ស្ពៃនាងវិលមក ព្រោះនាងដើររកផ្ទះរស់គ្មាន ។
៥.　ទើបចូលទៅទូលព្រះសាស្តា ព្រះអង្គទេសនាប្រោសប្រទាន
ពីធម៌សុខុមត្រៃលក្ខណ៍ញាណ ឱ្យនាងនោះមានប្រាជ្ញាថា ។
៦.　នាមរូបំអនិច្ចំ នាមរូបំទុក្ខំ នាមរូបំអនត្តា ភទ្ទេកិសាគោតមី ។
៧.　ម្នាលនាងគោតមីស្រីកិសា បើនាងដឹងថាជាគ្រាប់ស្ពៃ
ស្វែងរកគ្រប់ផ្ទះរួចហើយ នៃមិនបានគ្រាប់ស្ពៃមកធ្វើថ្នាំ ។
៨.　ព្រោះមានតែផ្ទះដែលគេស្លាប់ ចូរនាងចាំស្តាប់ពីផលកម្ម
ដែលតែងចូលជួយឧត្តម្ភ សត្វកើតព្រោះកម្មឱ្យកើតស្លាប់ ។
៩.　នាមរូបនៃសត្វមិនទៀងទេ កើតហើយជ្រេរទៅវិញឆាប់
តែងចាស់តែងឈឺតែងតែស្លាប់ ចូរនាងប្រញាប់ដកចិត្តចេញ ។
១០.　នាមរូបនៃសត្វនេះគ្មានសុខ តែងតែមានទុក្ខច្រើនពោរពេញ
ចូរនាងដកចិត្តពីកូនចេញ ហើយចូរបំពេញត្រៃសិក្ខា ។

១១, នាមរូបនៃសត្វមិនមែនខ្លួន ព្រោះមិនមាំមួនឥតខ្លឹមសារ
ជារបស់សោះសូន្យដោយសង្ខារ នឹងយកជាការគាប់ពុំបាន ។

១២, លុះដល់ចប់ព្រះធម៌ទេសនា នាងបានសោតាធម៌កល្យាណ
រំសាយក្តីសោកចេញចាកប្រាណ ស្ថិតនៅក្នុងឋានសាវ័កហើយ ។

១៣, យើងខ្ញុំអ្នកសូត្រសូមបារមី តេជះសិរីនាងដល់ត្រើយ
សូមឱ្យគ្រោះអ្នកបានសះស្បើយ ដោយគុណនិសង្សហោង ។

(ចប់)

## ព្រះអង្គប្រោសបិតា

១, នេះនិងថ្វាថ្លៃងចែងចរចារ កាលព្រះសម្មាសម្ពុទ្ធត្រាស់
បរមភិសេកឯកត្រចះ ទៀបអរុណរះស្វាងរស្មី ។

២, ក្នុងខែពិសាខជោគពិសេស ឈ្នះមារកិលេសលើលោកិយ៍
ក្រោយនោះសម្តេចព្រះជិនស្រី យាងចាកសសាវត្ថីនគរា ។

៣, ព្រះឧទាយីជាមគ្គទេសក៍ នាំពុទ្ធនិវេសចរលីលា
ចូរកាន់និគ្រោធអារាមជា វិហារប្រថាប់សម្រាប់គង់ ។

៤, គឺក្រុងកបិលភស្តុរាជបុរី ព្រះចមជិនស្រីថ្លៃវរអង្គ
ឈប់សម្រាកកាយដោយភិសវង់ ទើបទ្រង់រំពឹងដោយទិព្វញ្ញាណ ។

៥, ជ្រាប់ច្បាស់ថាព្រះអំពីមុន ទ្រង់ប្រោសបិតុគុណជាប្រធាន
តាមប្រពៃណីប្រដាប់បវេណីមាន ទើបទ្រង់ចាកឈានស្តេចគោចរ ។

៦, អរុណរៀងរះព្រះលោកនាថ ទ្រង់ឃ្លុំស្អាងស្អាតដោយចីវរ
ហើយទ្រង់កាន់បាត្រផ្ទាល់ព្រះករ មើលល្អឆព្ណណរន្ទាលឆ្នៅ ។

៧, ស្តេចទ្រង់ប្រទាន៧ចារឹក រង្សីសិតឥតមានហ្មងសៅ
ហើយទ្រង់ត្រាច់ត្រង់យាងសំដៅ ចូលទៅក្នុងទីនិវេសវាំង ។

៨, គឺក្រុងកបិលភស្តុរាជធានី ជាទីកំផែងវែងទូរទាំង
បរិវេណក្រឡាក្រាលព្រះទីនាំង ប្រាណសាទបល្ល័ង្គពង្សសត្យា ។

៩, ព្រះសង្ឃពីរម៉ឺនគ្រឿងតាមហែរ សុទ្ធតែកាន់បាត្រសុំអាហារ

រាស្ត្រពេញដីដែលខ្មែនសីមា យាត្រាតាមក្រោយព្រះអង្គទៅ ។

១០, ឯអស់បណ្ដាជនសាមញ្ញ ឃើញអរអញ្ជក្រួញក្រាបនៅ

ខ្លះលុតច្រត់ដៃដាក់លើភ្លៅ ខ្លះឱនទាបទៅដោយសិរសា។

១១, ខ្លះថ្វាយចង្ហាន់បិណ្ឌបាត្រ ខ្លះថ្វាយអភិវាទនមស្សការ

ខ្លះបាចកម្រងភួងបុប្ផា ខ្លះស្រែកហោថ្វាយពរជ័យ ។

១២, សំឡេងឮលាន់សន្ធឹកអាប់ ហាក់ស័ព្ទព្យុះខ្យល់ដល់ទីទៃ

ផ្លូកផ្អើលច្រួលខ្លាំងក្នុងវាងវៃ ជាអស្ចារ្យក្រៃក្នុងថ្ងៃនោះ ។

(ចប់)

## ទំនួញឳពុកម្ដាយ

១, កូនអើយកាលម្ដាយ នៅពីក្មេង និងឪពុកឯងសែនវេទនា

ខំប្រឹងចិញ្ចឹមកូនពុំងារ ឥឡូវក្លាយជាមនុស្សឥតន័យ ។

២, ចិត្តចង់រៀនសូត្រនូវធម៌អាថ៌ រក្សាសីល៥សីល៨

ជាប់ចិត្តនិងកូនស្ងួនពិសី រៀនធម៌វិន័យមិនចេះចាំ ។

៣, កម្មក្រាសខ្លាំងណាស់ដោយតណ្ហា មាតាបិតាប្រាថ្នាខ្លាំង

ចង់បានភោគទ្រព្យដោយកម្លាំង ទុក្ខគ្រាន់ចែកកើ្តកូនប្រុសស្រី ។

៤, ឱ្យកូនរៀនសូត្របានចេះដឹង មិនឱ្យល្ងិតល្ងង់ក្នុងលោកិយ៍

រៀបគូរភរិយានិងស្វាមី តាមច្បាប់វិន័យពីបូរាណ ។

៥, នឹកសង្ឃឹមថាខ្លួនចាស់ទៅ រំពឹងនៅលើកូនកល្យាណ

ថាមុខជាជួយខ្លួនវិញបាន ក៏សម្រាកប្រាណភ្លេចអាត្មា ។

៦, លុះដល់ខ្លួនចាស់កម្លាំងថយ ទើបបានតក់ស្លុតនិងសង្វារ

ក៏ចាប់តាំងរៀនសូត្រធម៌អាថ៌ ឯរូបកាយាដេកដួលហើយ ។

៨, កូនអើយនេះហើយកម្មឪពុកម្ដាយ ស្មានថារូបកាយមានខ្លឹមសារ

គ្មានធម៌អនិច្ចំនិងទុក្ខា ឥឡូវនេះណាចាស់ជរា។

៩, ព្យាធិចុកចាប់ជាប់រាងកាយ ធ្វើឱ្យរូបម្ដាយទុក្ខគ្រាំគ្រា

ពុំមានធម៌ណាមកភាវនា កាលខ្លួននៅជាធ្វេសប្រហែល ។

១០, រំពឹងអាចារ្យឱ្យពុទ្ធោ ត្រចៀកក៏ហឹងស្តាប់មិនច្បាស់
ខ្លួនឯងមិនដែលយល់ធម៌ព្រះ ទោះជាព្ធច្បាស់ថាមិនត្រូវ ។
១១, មិនបានហាត់កាយវាចាចិត្ត ឱ្យបានសុច្ចរិតទៅតាមផ្លូវ
ឱវាទព្រះពុទ្ធប្រៀនប្រដៅ ឥឡូវធ្លាក់ខ្លួនជិតមរណា ។
១២, មុននឹងមរណៈខ្ញុំសូមផ្តែផ្តាំ ប្រុសស្រីចង់ចាំស្តាប់ឱ្យច្បាស់
ជរាព្យាធិនិងមរណៈ គេមិនបញ្ជាក់សួរចិត្តឡើយ ។
១៣, រុករានទន្ទ្រានយករាល់ថ្ងៃ គួរតែកែខៃកុំព្រងើយ
ធ្មេញបាក់សក់ស្កូវអស់ទៅហើយ ម្តេចឡើយនៅតែមិនដឹងខ្លួន ។
១៤, គួរតែធ្វើទានរក្សាសីល ភាវនាកុំខ្ជិលឱ្យមាំមួន
កុំធ្វើដូចខ្ញុំៗខុសខ្លួន ព្រោះតែនិងកូនស្ងួនប្រុសស្រី ។
១៥, ខ្ញុំសូមផ្តែផ្តាំឱ្យជាក់ នូវធម៌ត្រៃលក្ខណ៍ជាវិន័យ
អនិច្ចំមិនទៀងរៀងរាល់ថ្ងៃ ទុក្ខអើយទុក្ខអ្វីទុក្ខឥតស្បើយ ។
១៦, អនត្តាប្រែថាមិនមែនខ្លួន ពិតជាមិនមែនខ្លួនយើងឡើយ
បើរបស់ខ្លួនឃាត់បានហើយ ម្តេចឡើយមិនស្តាប់បង្គាប់យើង ។
១៧, ថាតែប៉ុណ្ណេះបាត់ស្មារតី ធាតុក្តៅចេញធ្លុតដល់ចុងជើង
ឯកូនប្រុសស្រីឆោឡោឡើង ឪពុកម្តាយយើងគាត់ស្លាប់ហើយ ។
១៨, ស្តាយអើយសែនស្តាយគាត់ស្លាប់ទៅ កូនចៅមិនទាន់
បានដឹងគុណមាតាបិតាមានគុណធ្ងន់ រកអ្វីស្មើរផ្ទឹមប្រៀបពុំបាន ។
១៩, ពេលនេះកូនមកជួបជុំគ្នា កូនសូមវន្ទាលាទោសហើយ
កាលលោកនៅរស់ខ្ញុំកន្តើយ ដោយពាក្យសម្តីមិនសមរម្យ ។
២០, អញ្ជើញងូតទឹកណាអ្នកម្តាយ ដុសសំអាតកាយដោយដៃខ្លួន
ឡើងលើព្រះឋានបានសមរម្យ កូនសូមធ្វើទានជូនទៅអ្នក ។
២១, មានភ្លេងពិណពាទ្យ ដូរតន្ត្រីស្លាដកសង្ឃថ្មីនឹងភេសជ្ជៈ
បង្អែមចង្ហាបលើកឡើងដាក់ ចំពោះព្រះភ័ក្ត្រសង្ឃត្រៀបត្រា ។
២២, នេះហើយថាអ្នកចេះធ្វើបុណ្យ តបគុណមាតានិងបិតា

ជូនចំណីម្ហូបនិងអាហារ ឱ្យគាត់ពិសារទាន់រស់នៅ ។

២៣, ឥឡូវគាត់ស្លាប់បាត់ទៅហើយ កូនចៅខាងក្រោយធ្វើផ្ញើទៅ
មិនដឹងកន្លែងដែលគាត់នៅ មិនដឹងថាដល់ឬមិនដល់ ។

២៤, នេះលោកអើយខ្ញុំខុសហើយ បងប្អូនខាងក្រោយកុំងឿងឆ្ងល់
ឪពុកម្ដាយរស់ត្រូវតែផ្ដល់ នេះជាកុសលយើងឃើញពិត ។

២៥, ខ្ញុំនេះជាកូនអកតញ្ញូ តស៊ូម្ដាយអស់ជីវិត
កាលគាត់នៅរស់ខ្ញុំមិនគិត ញាតិមិត្តកុំយកតម្រាប់ខ្ញុំ ។

(ចប់)

## ខមាទោសឪពុកឬម្ដាយស្លាប់

១, កូនសូមឱនកាយថ្វាយវន្ទា បង្គំខមាទោសផ្សេងៗ
ដែលកូនខុសហើយតាំងពីក្មេង កាយចិត្តវង្វេងនឹងវាចា ។

២, សម្ដីធ្ងន់ស្រាលកូនពុំបានដឹង តតបមាត់រឹងតែងឆ្លើយឆ្លង
ឯកាយទៀតសោតក៏កន្លង ឆ្គាំងឆ្គងពុំសមអធ្យាស្រ័យ ។

៣, បពិត្រព្រះមេមានគុណធ្ងន់ សូមលោកអត់ធន់ដល់កូនណា
អនុគ្រោះអនុញ្ញាតិនូវទោសា ដល់កូនគ្រប់គ្នាដោយសន្ដោស ។

៤, ពេលនេះកូនសូមដង្ហែរព្រះ លើកចេញពីផ្ទះទៅទីបច្ឆារ
កូនទាំងអស់គ្នាសែនខ្លោចផ្សារ រងទុក្ខវេទនាស្ទើរក្សិនក្ស័យ ។

៥, សូមលោកឪពុក(អ្នកម្ដាយ)ទៅឱ្យបានសុខ ដល់ឋានផុតទុក្ខនិព្វាន្ធថ្លៃ
ធ្វើម្ដេចជាតិនេះឪពុក(អ្នកម្ដាយ)អាយុខ្លី ចោលកូនប្រុសស្រីឱ្យកំព្រា ។(ចប់)

## *បូជាព្វូនឆ្អឹខ្សាច់លាគម្ពៀវ*

១, អហ៊ីរយើងខ្ញុំថ្វាយបង្គំ វន្ទានិមន្ត ខ្សាច់នេះណា
សូមប្រាថ្នា សាងចេតិយ៍ ។

២, ខ្ញុំសូមលាកម្មពៀរ បាបវេរាខ្លួនខ្ញុំក្ដី
បាបលោកនាលោកិយ៍ កុំបីមានក្ដីសៅហ្មង ។

៣, ខ្ញុំរំលឹកគុណទេវតានៅសួគ៌ា ស្រឡះហោង

ព្រះឥន្ទ្រយមរាជផង នឹងសរណំជាសាក្សី ។

៤, កាលខ្ញុំពីក្មេងមក ចិញ្ចឹមជ្រូកគោក្របី
មាន់ទាសម្លាប់ត្រី ចាប់លក់ដូរចិញ្ចឹមប្រាណ ។

៥, ខ្ញុំសូមលាទោសនោះ ដែលខឹងខុសមោះសាមាណេ
ប្រមាថញាតិសន្តាន ទោះព្រៀងលានអ្នកដ៏ទៃ ។

៦, ប្រមាថនូវព្រះពាយ ភិរុណនាយព្រះម្ចាស់ថ្លៃ
ប្រមាថជេរទឹកដី កាប់ព្រៃឈើប្រពៃសព្វ ។

៧, ប្រមាថខ្លួនឯងណា តួរអក្ខរាបង្កើតសព្វ
ពួធមិហើយខឹងស្អប់ ប្រមាថដល់កូនអាចារ្យ ។

៨, ខ្ញុំសូមលាទោសខ្លួន ជេរជីដូនជេរជីតា
ប្រមាថព្រះមាតាព្រះបិតា នឹងរៀមច្បង ។

៩, ទោសនោះយមបាល នឹងត្រកាលគេចាប់ចង
ទេវតារក្សាគ្រង កត់បញ្ជីសម្គាល់ទុក្ខ ។

១០, ខ្ញុំធ្វើបុណ្យគ្រប់មុខ សូមប្រាថ្នាឱ្យបានសុខ
សម្រេចទៅនិព្វានហោង ។ (ចប់)

## ខមាទោស

១, កូនសូមគោរព គុណធ្ងន់លើសលប់
គឺគុណទាំងពីរមាតាបិតា គុណលោកទាំងទ្វី
គ្មានអ្វីប្រៀបបាន ។

២, កូនសូមខមាទោស ក្រែងកូនធ្វើខុស ពីមុនប៉ុន្មាន ទោសតូចធំក្តី
ប្រុសស្រីគ្រប់ប្រាណ មិនអាចចាំបាន ខុសច្រើនប្រការ ។

៣, មួយខុសផ្លូវចិត្តមិនបានជាគិត ពីខុសវាចាហាស្តីនិយាយ
ធ្លោយហួសមាត្រា បើមានពេលណាប៉ះពាល់ដល់កាយ ។

៤, កុំហុសទាំងបី កាលកូនគ្មានវ័យ ប្រុសស្រីទាំងឡាយ
មិនទាន់ចេះគិតគំនិតវែងឆ្ងាយ មានខុសខ្លះហើយព្រោះតែសប្បាយ ។

៥, កុំហុសទាំងអស់កូនសូមខមាទោស លោកឪពុកអ្នកម្ដាយ
សូមអភ័យទោសកូនទាំងឡាយ កូននៅជិតឆ្ងាយសូមរួចទាំងអស់ ។

៦, អហោសិកម្មពាក្យបាលី ចាំគ្មានសល់ចន្លោះសូមរួចទុក្ខភ័យ
កម្មពៀរទាំងអស់ រួចផុតស្រឡះ ពេលនេះទៅហោង ។

(ចប់)

## បុណ្យកតញ្ញូ

១, ឱ:ឱលោកមាតាបិតា ថ្ងៃនេះអស្ចារ្យពន់ពេកក្រៃ
រូបកូនទាំងអស់នឹកមមៃ ដល់គុណមាតានិងបិតា ។

២, កូនបានរៀបចំបុណ្យថ្ងៃនេះនៃ បុរាណស្រដីថាទក្ខិណា
វត្ថុទាំងឡាយនេះឯងណា នៅលើហត្ថាកូនគ្រប់ប្រាណ ។

កូនលើកសំពត់ខោអាវ និងបច្ច័យជូនដល់មាតាបិតាសូត្រថា

១, កូនសូមបង្អោនលើកថ្វាយព្រះ ក្នុងពេលនេះច្បាស់នឹងនេត្រា
សូមលោកទទួលដោយករុណា មេត្តាអាណិតដល់កូនផង ។

២, កូនក៏សូមស្មាលាទោស ក្រែងមានកំហុសខុសច្រើនដង
ដោយកូនល្ងង់ខ្លៅពុំដឹងផង សូមព្រះច្បាស់ច្បងអត់ទោសស្បារ ។

៣, បពិត្រលោកមាតាបិត កូននឹកខ្លោចផ្សារពេកអំបាយ
តាំងពីកូនកើតមានរូបកាយ អ្នកតែងខ្វល់ខ្វាយថែរក្សារ ។

៤, ឱ:ឱម្ចាស់ថ្លៃវិសេសលន់ អ្នករងទុក្ខធ្ងន់ពេកណាស់ណា
ព្រោះអ្នកខំបីបាច់ស្ងួនភ្ងារ ពុំអាចពណ៌នាឱ្យអស់បាន ។

៥, ដូច្នេះកូនសូមផ្គងអញ្ជលី លើកហត្ថទាំងពីរបន្ទន់ប្រាណ
បង្គំបាទាព្រះក្សេមក្សាន្ត ទោសខុសប៉ុន្មានសូមប្រណី ។

៦, រហូតដល់កូនធំពេញវ័យ មានប្រពន្ធប្ដីក្រុមគ្រួសារ
ដោយក្ដីសន្ដោសកូនរាល់គ្នា មានព្រហ្មវិហារមកលើកូន ។

៧, ព្រោះកូននៅល្ងង់មិនស្គាល់គុណ កាលពីមុនដោយមោហបិត
សូមមានខន្តីមេត្តាចិត្ត អាណិតសន្ដោសទោសកូនផង ។

(ចប់)

## ទំនួញព្រះព្រហ្ម

១. ព្រះព្រហ្មឈរយំទឹកស្រណោះ ព្រហ្មយំព្រោះអស់ក្ដីសង្ឃឹម
ទឹកភ្នែកជ្រែកភក្ត្រធ្លាប់ញញឹម ទុក្ខឥតអ្វីផ្ទឹមពេលនេះម្ដង ។

២. ព្រហ្មវិហារធម៌ទាំងបួន គិតថាមាំមួនអាចចម្លង
កូនស្ងួនឱ្យផុតក្ដីមួរហ្មង ដល់ត្រើយសុខផងលុះមរណា ។

៣. ឥឡូវមិនបានដូចការគិត ព្រហ្មឈរអាណិតបុត្រសង្សារ
ឃើញកូនធ្លាក់ខ្លួនគួរអនិច្ចា បង្កបញ្ហាក្នុងជីវិត ។

៤. ឈ្លក់ល្បែងប៉ោបៀរគ្នាគូកន វង់ល្បែងបារបនងប់ងឹត
ងងល់វិលវល់ក្នុងគំនិត ប្រព្រឹត្តទុច្ចរិតឥតពិចារ ។

៥. កូនក្លាយជាមនុស្សបាតសង្គម ទ្រូងម្ដាយក្ដៅងំក្រំខ្លោចផ្សារ
ដូចភ្នំសង្កត់លើឱរ៉ា ខ្មាសញាតិការក្នុងភូមិស្រុក ។

៦. ទោះជាយ៉ាងណាក៏ដោយក្ដី ម្ដាយក្នុងលោកិយ៍ឥតរើសមុខ
ប្រាថ្នាឱ្យកូនបានក្ដីសុខ រួចផុតចាកទុក្ខគ្រប់វេលា ។

៧. ទោះម្ដាយលំបាកក្រៃយ៉ាងណា សូមកូនសង្សាររួចចាកពៀរ
រួចពីគំនិតគិតពាលា ជាមនុស្សល្អជាសង្គម ។

៨. ទឹកភ្នែកជាន់ជោរហូរជោគភក្ត្រ សូមជួយពញ្ញាក់ចិត្តកូនខ្ញុំ
ឱ្យកែខ្លួនបានយ៉ាងសក្ដិសម ជួបក្ដីសុខុមតរៀងទៅ ។

(ចប់)

## ទំនួញនាងហិភារធទី

បពិត្រភស្ដា ពិម្ពិសារម្ចាស់អូនអើយ
កម្មតាមមកផ្ដល់ហើយ អម្ចាស់អើយរងវេទនា។
លំបាកចិត្តស្ទើរធ្លាយ ឈឺសព្វកាយម៉ាយចិន្ដា
ឃើញអង្គព្រះភស្ដា ជាន់ពន្ធនាបួនសឹងក្ស័យ ។
ធ្វើម្ដេចកម្មព្រះអង្គ ដែលទ្រង់សាងណាក្សត្រថ្លៃ

រងទុក្ខពន់ពេកក្រៃ អ្នកដទៃជួយពុំបាន ។
ឱៈឱព្រះភស្តា ខ្ញុំទស្សនាព្រះរូបប្រាណ
ឃើញអង្គម្ចាស់ក្សត្រក្សាន្ត ធ្វើម្តេចបានចូលទៅជិត ។
ប្អូនឃើញព្រះរូបទ្រង់ ជាពូជពង្សជីវិត
ជាប់ក្នុងគុកងងឹត ជាទីបំផុតពេលនេះហើយ ។
សូមក្រាបបាទា លើហត្ថាមិនព្រងើយ
ផ្តិម្រាមទាំងដប់ហើយ អម្ចាស់អើយប្អូនសូមទោស ។
សូមព្រះអង្គចមពល ស្រស់និមលអត់កំហុស
ដែលប្អូនប្រព្រឹត្តខុស និងព្រះអង្គព្រះភស្តា ។
ព្រះនាងសូមអភ័យ នឹងក្សត្រថ្លៃម្ចាស់សិរីសា
ស្រេចថ្វាយបង្គំលា ទៅដំណាក់ព្រះនាងវិញ ។
ធេងធោងអស់កាយា ចុកឈឺផ្សាទុក្ខទោម្នីញ
យាងទៅប្រាសាទវិញ ស្មើនិងក្ស័យក្នុងគ្រានោះ ។

(ចប់)

## សូត្រពេលស្រង់ព្រះរស់

១. កូនសូមស្រោចស្រង់ សុគន្ធវារី លើកហត្ថទាំងពីរបីត្រកង
ជម្រះមន្ទិលគ្រឿងសៅហ្មង ដែលខុសកន្លងរួចមកហើយ ។
២. តាំងពីកូនកើតនៅតូចខ្ចី ម្តាយថ្នាក់ថ្នមបីថែរក្សា
លោកម្តាយភ័យព្រួយពេកណាស់ណា រងទុក្ខវេទនាដោយសារកូន ។
៣. ហេតុនេះកូនសូមខមាទោស ដែលបានធ្វើខុសទាំងប៉ុន្មាន
សូមលោកប្រណីខន្តីប្រាណ ទើបបានសុខសាន្តតរៀតទៅ ។

(ចប់)

១ / ទេសនាបានចប់ហើយ ព្រះគុណអើយសែនសង្វេគ

ពុទ្ធដិការល្អអំណែក យកមកចែកជូនយាយតា ។
ស្តាប់ហើយពិចារណា រឿងសង្ខារមិនទៀង
គួរខំរិះរេទាំងយើង គេស្តាប់ឱ្យបាន ។
ពាក្យល្អកម្រមាន ព្រះប្រទានដល់យើងហើយ
យកទៅមិនខុសឡើយ លុះដល់ត្រើយថ្លៃថ្លាណាស់ ។
ចំណែកពាក្យពិស្តា អង្គទេសនាពិរោះក្រៃ
ចង់ស្តាប់ពេញមួយថ្ងៃ លោកតាយាយដូចខ្ញុំទេ ។
ព្រះភ័ក្រ្តនៃអង្គម្ចាស់ រីករាយណាស់បានប្រោសសត្វ
ឱ្យយល់ហេតុជ្រាបច្បាស់ ឥតមានខ្លះថ្ងៃនោះហោង ។
អភ័ពនូវរឿងមួយ កើតទុក្ខព្រួយសែនចំបែង
ព្រះគុណទេសក្តែង១ អកុសលតែងឯងសោត្តាថ្លង់ ។
រឿងមានដូចតទៅ លោកតម្រូវហៅថាកម្ម
ងងឹតទាំងឆ្វេងស្តាំ ចង់ចំណាំព្រះភ័ក្រ្តថ្លៃបពិត្រ ។
នៃព្រះគុណដ៏មានបុណ្យ ធំក្រៃណាស់មកប្រោស
ពុទ្ធបរិស័ទសូមបានត្រាស់ ខាងមុខហោង ។

(ចប់)

## បទព្រហ្មអារធនា

រីព្រហ្មខ្ញុំជាធំ ក្រៃលែងព្រហ្មផងទាំងឡាយ
ចុះមកលុតអង្គកាយ លើកហត្ថ ថ្វាយនមស្សការ ។
បពិត្រព្រះអង្គអើយ ព្រះគុណល្ហើយសូមមេត្តា
សម្តែងព្រះធម្មាប្រោស ទេសនា នូវមនុស្សសត្វ ។
ត្បិតសត្វងងឹតណាស់ មិនបានច្បាស់ផ្លូវអរហត្តព្យាយាម
តាមប្រតិបត្តិ នឹងកំចាត់ចាកកងទុក្ខ ។
ព្រោះហេតុតែមោហៈ នីវរណៈធម៌ទាំងឡាយ
បិតបាំងសន្តានកាយ វង្វេងឆ្ងាយពីត្រៃលក្ខណ៍ ។

នឹងរកលោកណាមួយ ឱ្យមកជួយស្រោយអន្ទាក់
មានតែព្រះអរិយៈ នោះលោកជាក់ច្បាស់ស្រោយបាន ។
ហេតុនេះសូមព្រះអង្គ ជួយស្រោចស្រង់ទ្រង់ប្រោសប្រាណ
ព្រហ្មខ្ញុំតែងរាប់អាន ចុះមកថ្កានអារធនា ។

(ចប់ដោយបរិបូរណ៏)

## សុខុមលក្ខណៈ

## ស្តីពីខន្ធ៥

ខន្ធ៥មិនទៀងតែងល្បៀងឃ្លាត លោកធាតុទាំងអស់ឥតសល់អ្វី
កើតស្លាប់ៗកើតកំណើតថ្មី ឥតបីស្រាកស្រានគ្រប់ប្រាណសត្វ ។
ជរាគ្រាំគ្រាជាធម្មតា ខន្ធ៥ក្តីណាក៏វិបត្ត ឃ្លាតចាកការពិតឫទ្ធិស្ងប់ស្ងាត់ ឥតអ្វីបញ្ញត្តឱ្យទៀងបាន ។
រូបក្ខន្ធមិនទៀងគ្រប់ៗថ្នាក់ ធ្មេញបាក់សក់ស្កូវឥតសល់ខាន
ភ្នែកប្រែបែរជាស្លាស់មិនបាន ទីស្ថានប៉ុន្មានវង្វេងវល់ ។
ត្រចៀកច្រមុះអណ្តាតកាយ ប្រែក្លាយទាំងអស់ឥតមានសល់
សំឡេងក្លិនរសសម្ផស្សផល វិលវល់ឈប់ដឹងដំណឹងសព្ទ ។
ធម៌ណាមិនទៀងតែងល្បៀងឃ្លាត ធ្វើឱ្យលោកធាតុប្រែត្រឡប់

ធម៌នេះជាទុក្ខមុខគួរស្អប់ មិនមានពេលចប់ចុះសោះឡើយ ។

(ចប់អនិច្ចាទី១)

## ទុក្ខតាទី២

រូបកាយទាំងឡាយនៃពួកសត្វ វិបត្តិមិនខុសទេអ្នកអើយ

ទាំងឡាយចេតសិកក៏ឥតស្បើយ ខន្ធ៥នេះហើយសឹងដូចគ្នា ។

ទុក្ខខ្លះប្រព្រឹត្តទៅតាមកាយ ខ្លះផ្សាយទៅតាមមនោទ្វារ

ទទួលយកទុក្ខទៅទំពា វេទនាក៏សោយតាមអារម្មណ៍

សញ្ញាសង្ខារនិងវិញ្ញាណ ទទួលសោយបានដោយនិយម ក្រេបយកក្តីទុក្ខក្តៅ អួលធំ

ទាំតូចទាំងធំមិនសល់ខាន ។

ទុក្ខនេះឈ្មោះដើមមាន១០កង សត្វផងកន្លងឆ្លងមិនបានលោក៣

ជាមុំដូចជើងក្រាន ទ្រទុក្ខឥតក្សាន្តខានពេលណា ។

ធម៌ដែលធ្វើសត្វឱ្យកើតទុក្ខ ឥតសុខសប្បាយកាយចិត្ត

ធម៌នេះជាឈ្មោះទុក្ខតា សាស្តាទេសនាថាត្រៃលក្ខណ៍ ។

(ចប់ទុក្ខតាទី២)

## អនត្តាទី៣

អនត្តាប្រែថាមិនមែនខ្លួន សោះសូន្យមិនមួនគ្រប់ថ្នាក់

រូបកាយទាំងមូលអប្បលក្ខណ៍ គ្រប់រូបនាងអ្នកទាំងប្រុសស្រី ។

មិនមែនរបស់យើងទេណា កាយចិត្តវាចាទ្វារទាំង៣

លោកនេះឬលោកខាងមុខក្តី បុរីរម្យរដ្ឋរាជសីមា ។

ទោះបីបង្គាប់ប្រាប់ពន្យល់ ក៏ឥតបានផលសមប្រាថ្នា

ដូច្នេះនេះឈ្មោះអនត្តា ប្រែថាមិនមែនខ្លួនសោះឡើយ ។

(ចប់អនត្តាទី៣)

## ព្រះត្រៃលក្ខណ៏សង្ខេប

រូបំ ទុក្ខំ ទុក្ខអើយទុក្ខខ្លាំង ខ្លាំងពន់ប្រមាណ ពីតូចដល់ធំ
ទុក្ខទុំក្នុងប្រាណ ទុក្ខឥតស្រាកស្រាន្ត ទុក្ខដល់ខ្លួនក្ស័យ ។
អនិច្ចំពុំឋិត ពុំថេរនៅនិត្យ យឺនយូរឡើយ
ស្លាប់ទៅជាខ្មោច អាសោចីពេកក្រៃ ឆ្អឹងសាច់សរសៃជាធរណី ។
អនត្តាសូន្យសោះ សូន្យរូបសូន្យឈ្មោះ សូន្យមគ្គសញ្ញី
សូន្យយសសក្ដា ធិការសោភី សូន្យសព្វឥន្ទ្រីយ៏ មាសប្រាក់អន្តរាយ ។
ដូច្នេះគួរគិត គួររក្សាចិត្ត ខឹងឆាប់រសាយ ចិស្ដូនទន់ទោន ដូចកូននិង ម្ដាយ ខឹងឆាប់រសាយ
សូន្យបាត់ទៅហោង ។

(ចប់ព្រះត្រៃលក្ខណ៏សង្ខេប)

## រូបក្ខន្ធោ

រូបក្ខន្ធោ មានធាតុអាបោ តេជោបឋវី ជីវ្ហាចក្ខុន្ទ្រីយ៏
សោតតិន្ទ្រីយរាល់រូបឥន្ទ្រីយ ប្រុសស្រីទាំងឡាយ ។
គួរគិតអនិច្ចា រូបអើយមរណា ពិបាកក្នុងកាយ បំរើព្រះយម
គេដំគេវាយ គេចងរូបកាយ គ្រប់ប្រាំប្រការ ។
ខ្យល់បក់ថយឡើង ថយពីបាទជើង ថយពីហត្ថា ហត់បាត់សន្ធប់
ខំទប់ហើយថា លោកអើយ មេត្តា រងចាំកូនខ្ញុំ ។
រីមច្ចុះកម្មា ក្រេវក្រោធហើយថា រើយគ្នាយើងជុំ ម៉ឹងចោរកំណាច
អាសាវព្រះយម ថាឯងនេះខំ រកដួងកែវណា ។
បើដល់កំណត់ ម៉ឹងឯងសន្មត នឹងយើងប្ដេជ្ញា ឥឡូវប្រកែក  អស់ឯករេវា ម៉ឹងផ្ដាំអ្នកណា យើងពុំព្រមឡើយ
។
មច្ចុៈកម្មស្ដាប់ ចុកសោះប្រញាប់ គ្រប់ទ្វារអស់ហើយ អណិតខ្លួនពេក
ស្រែកយំខ្សើយៗ ម៉ែឪខ្ញុំអើយ អាណិតជួយកូន ។
អយំកាយោ ធូរេនិត្តោ ចោលរូបសោះសូន្យ ធាតុភ្លើងក្ដៅដល់
ធាតុខ្យល់ក្នុងខ្លួនដង្ហើមធួនៗ ចេញច្រើនចូលតិច ។

ហត់អើយហត់ណាស់ ខំប្រឹងប្រែប្រាស់ ស្ដីពូតិច១ហៅបងហៅប្អូន
កូនអើយគិតម្ដេច បានធូរបន្តិច ផ្ដាំកូនប្រពន្ធ ។
អំពើកម្មដល់ ដង្ហក់យកខ្យល់ ទុរាទុរន់ធុរៈក្នុងខ្លួន មាំមួនពេកពន់
គេអាណិតលន់ ជួយឃាត់ពុំបាន ។
អស់ញាតិបងប្អូន ម្ដាយប្រពន្ធកូន បន់ស្រន់ស៊ាន់១បន់តែបង់មាត់
ឥតឃាត់កម្មបាន កម្មត្រូវគ្រប់ប្រាណ រាល់រូបប្រុសស្រី ។
និសាសៈវាទ អស្សាសឃាត់ បស្សាសន័យ ខ្យល់ចេញមិនចូល
រមួលសសៃ ហាសិបប្អូននៃ ដង្ហើមមរណា ។
អង្គអគ្គណនា ឯកអានាថា ឥតគេជាគ្នា ព្រលឹងក្នុងខ្លួន
មាសស្ងួនរូបា ចតុភូត្តោ លាអ្នកទៅហើយ ។
ភូតប្អូននេះណា មិនដឹងអាត្មា សើចលេងព្រងើយ គេសែងរូបទៅ
ដល់ព្រៃជ្រៅហើយ កប់ស្រេះដើរតើយ គូសដីជើងក្អែក ។
វិភូតទាំងប្អូន លេងយូរភ្លេចខ្លួន អល័យផ្ទះពេក ដើរចេញពីព្រៃ
ឃើញដីជើងក្អែក ដល់ផ្លូវបំបែក គេស្រេះបន្លា ។
ឈរឈប់រេរា រំពឹងគិតគ្នា នេះហើយនរណា ថារូបយើងស្លាប់
គេកាប់សម្លាប់ គេគូសដីវា មិនឱ្យទៅឡើយ ។
បែររាប់ម្រាមដៃ ឃើញតែប្អូននៃ បាត់មួយទៅហើយ រូបស្លាប់មែនពិត
តាំងស្រែកយើង អម្ចាស់កូនអើយ ចោយកូនអាសារ ។
ស្អប់រូបកូនណាស់ មិនទុកលើផ្ទះ កប់ជិតទៅវ៉ា នៅក្នុងរបស់
ជិតថងមិនថា ម្ដេចចោលអាសារ ក្នុងព្រៃសូន្យឈឹង ។
ម៉ែអើយកូនខ្លាច សត្វផងសឹងកាច សាហាវជុំខ្លួន ទីទុយខ្លែងស្រាក
មានសត្វមៀមមុំ អាសូររូបកូន ឥតអ្នកជាគ្នា ។
ព្រៃស្ងាត់ជ្រងំ ខ្លាតូចខ្លាធំ ខ្លាដំបងណា ចចកដីរ ឆ្កែព្រៃត្រៀបត្រា
ឱ្យរូបកូនអើយ កំព្រាម្នាក់ឯង ។
យំអើយរែងយំ ឈរជើងទន្ទ្រាំ ទូលដៃក្ដែង១ ពីព្រឹកលុះថ្ងៃ

ជិតព្រៃទួញតែង យំតែម្នាក់ឯង គ្រប់ពេលវេលា ។
អង្គុយជិតនៅ ប្របមាត់រណ្តៅ អនិច្ចារូបថា ឱរូបអើយហើម
សម្បើមនេត្រា ករួញស្មើស្នា ភ្នែកល្បៀនស្មើរធ្លាក់ ។
ជើងដៃក្រញ៉ង់ រាងរលស្រទាង ឈាមហូរស្រស្រាក់ គ្រប់ទ្វារទាំងបួន
ពាសខ្លួនប្រឡាក់ ចេះតែហូរធ្លាក់ ដាប់ដល់ធរណី ។
លុះប្រាំពីរថ្ងៃ ហើមដាច់សសៃ គង់តែឆ្អឹងទេ រលួយរលេះ
ធ្លាក់ចុះឥតល្ហែ គ្មានសល់ទំនេរ អស់រូបយើងអើយ ។
ចតុភូត្តោ សល់សែនទុក្ខោ ស្រែកយំខ្ញើយៗ ច្រើនខែច្រើនថ្ងៃ
ក្រក្រីហៅស្បើយ អត់ឃ្លានណាស់ហើយ យកស្ពបទទូរ ។
ដើរសុំភូមិគេ ដើររកស៊ីពៃរ ជាអន្លង់យូរ លុះសោះអស់ឆ្អឹង
រំពឹងបានធូរ អន្ទោលជាតោ សន្សឹមតទៅ ។
អ្នកអើយសង្វាត់ រៀនដឹងគុណធាតុ ទាំងក្នុងទាំងក្រៅ នឹងបានរំដោះ
នាំអស់ភូតទៅ បំបែកខាននៅ រងទុក្ខច្នេះណា ។
អ្នកអើយនាអើយ រូបរសនៅឡើយ គួរនៅអនិច្ចា ត្រង់កម្មកាមរាគ
លំបាកណាស់ណា ត្រូវគ្រប់អាត្មា ប្រុសស្រីទាំងឡាយ ។
គួររកកាន់សីល ភាវនាកុំខ្ជិល ឧស្សាហ៍ស្វាធ្យាយ មានទ្រព្យធនធាន
អោយទានទាំងឡាយ កុំគិតសោកស្តាយ កុំលោភពេកពន់
ចូលរៀនបរមត្ថ ខន្តីពាក្យសត្យ ឧស្សាហ៍ធ្វើបុណ្យ កតញ្ញូតា
ស្នេហាតបគុណ ចូរស្រឡាញ់បុណ្យ ជាធនទៅមុខ ។
ព្រះយមឧឱ្យពរ ឥន្ទព្រហ្មសាទរ ចំរើនឱ្យសុខ ឡើងលើសួគ៌ាឋាន
ខុសខាននរក ជៀសចាកភូមិភព ភ័យចតុរាបាយ ។
ហៃសាធុវោ សាធុនរោ ប្រុសស្រីទាំងឡាយ ចូរត្រង់ចូរត្រាប់
ចូរស្តាប់អធិប្បាយ ព្រះធម៌មិនងាយ បន្ទុកបរមត្ថ ។
ក្រអើយសែនក្រ ក្រក្រៃទ្រព្យធនធាន សូន្យយានសម្បត្តិ
កែវកងមុនីរតន៍ សូន្យសោះខាននៅ ។

តែស្លាមួយមាត់ រលាយទៅបាត់ នឹងខ្លួនដោយផ្លូវ ប្រាក់ស្លឹងបង់មាត់

ចេះស្អិតសល់នៅបើគេដើរទៅ គេរើសយកវិញ។

អ្នកអើយនាងអើយ រូបរស់នៅឡើយ ឧស្សាហ៍អស់អញ

បំពេញសីលទាន ជាស្ពានទៅវិញ ភាវនាទន្ទេញ បាននិព្វានហោង ។

(ចប់)

## ម្តាយបំពេរកូនដោយទឹកចិត្តស្រឡាញ់

## កុមារពិលាប

ឱ! គួរសង្វេគដល់កុមារកាលនោះបិតាអោយទានព្រាហណ៍

ជូជក់សំឡុតវាយគំរាម ដោយខ្លាចព្រាហណ៍វាយឈើខ្លោចផ្សា ។

កុមារយំថ្ងូរអាសូរពេក ហូរល្វែងទឹកភ្នែករែងខ្លោចផ្សា

ទ្រង់ព្រះកន្សែងពិលាបថា ឱ៎! បិតាម្ចាស់កូនអើយ ។

ស្ដេចពុំប្រណីកូនសោះឡើយ កម្មអើយខ្ញុំរង់វេទនា

ឃាត់ព្រាហណ៍កុំអាលទាន់យាត្រា ឱ្យស្បើយក្នុងប្រាណបានសុខា ។

គ្រាន់យល់ភក្ត្រាព្រះមាតា លុះត្រាតែបានអោយជួបជុំ

ឱព្រះគុណម្ចាស់ខ្ញុំអើយ ម្ដេចឡើយពុំទ្រង់ប្រោសមាតា ។

ក្រែងរសៀលសុរិយាម្តាយមកដល់ គ្រាន់កូនបានយល់មុខមាតា
ឱនាងកណ្ហាពៅបងអើយ ទុក្ខធំពុំស្បើយក្តៅក្នុងកាយ ។

## ទំនួញកុមារឡើងពីស្រះ

ជាលីស្រែកហៅទៅក្រឹស្នា កុំអោយបិតាហៅច្រើនដង
កម្មយើងទេប្អូនទទួលរង កន្លងមិនផុតទេពិសី ។
ជាលីក្រឹស្នាប្អូន និងបង ឡើងមកត្រសងពីស្រះស្រង់
ចូលគាល់បិតាជារាជវង្ស លំទោនកាយអង្គក្រាបវន្ទា ។
ប្រឹងចូលអង្វរទាំងពីរនាក់ ទឹកនេត្រសស្រាក់ស្រោចចង្ការ
ថាឱ!ម្ចាស់កូនខ្ញុំកំព្រា ចាំព្រះបិតាខ្ញុំមកសិន ។

## ទំនួញមទ្រីលក្ខណា

ឱះ!ឱ...អៃយ៉ារីយ ព្រះសុរិយា..ថ្ងៃក៏កាន់ទន់ទាប បិទបាំង
ព្រះច័ន្ទចែងចាំង ថ្លាយង់ តារារះរាយរៀងរហង់ រស្មីត្រចង់ ត្រចែនថ្លា
ពពក រសាត់ខ្ពស់ត្រសែត អណ្តែតល្មើនលះអាកាសា ។
នាង...ក៏ព្រះយោគសោកាថា...អះអាំ កណ្ហាកូនស្រីមាសម្តាយអើយ
ឱព្រះសុរិយាព្រះសុរិយា ម្តាយលឺមាត់មាន់ព្រៃរងាវឆ្លើយ តាវៅយំលន្លោចម្តាយស្តាប់មាត់ ទូចយំល្ហើយៗ ។
ឱសត្វសារិកាកែវអើយ ម្តេចអ្នករួមនិងម្តាយអ្នកឯអញ កូនវលក្ខណ៍
ព្រាត់ប្រាស់មិនឃើញឡើយ ។
ជាលីក្រឹស្នា កូនស្រីមាសម្តាយអើយ កូនអើយកូនអ្នកមករកថៅម្តាយ
ខ្លាចក្រែងក្រឹស្នាស្រីពៅម្តាយ ស្រេកទឹកឃ្លានបាយ រកដោះថៅ ។
ថ្ងៃនេះបង្កើតជាអស្ចារ្យ ម្តាយរកផល្លាក្នុងព្រៃជ្រៅ
ពុំសូវមានផ្លែណាឆោមឆៅ កូនក្តៅក្នុងទ្រូងពុំមានស្បើយ ។
ទើបនាងខំវិលត្រឡប់មកអំពីព្រៃ ស្រាប់តែទើបពះប្រទះនឹងសត្វទាំង
បីគឺសត្វរាជសីហ៍ ខ្លាធំ ខ្លាដំបង បណ្តើរគ្នាត្រសងមកពារគ្នា
ពាំងនឹងផ្លូវ....នាងដើរទៅពុំបាន ក្សត្រីកន្សាណ ក៏លុតលើកកំបង់
អញ្ចលីលួងលោមថា ។

ឱសត្វម្រឹកទាំងបី សូមអ្នកបើកផ្លូវអោយខ្ញុំយាត្រា ខ្ញុំនឹងនាំអាហារទៅថ្វាយ

ក្សត្រទាំងបីអង្គ ដែលក្សត្រគង់ឯអាស្រមបរមសាលា អះអាព្រះគុណខ្ញុំ

អើយព្រះគុណ... ។

(និយាយ)

ឯសត្វម្រឹកទាំងបីលឺនាងលួងលោមអង្វរដូច្នោះហើយ ក៏រឹងរិតតែ

ធ្វើសំឡេងអោយខ្ទរខ្ទារ នាងក៏បានដួលសន្លប់បាត់ស្មារដី ឯសត្វម្រឹកទាំងបី

ឃើញនាងសន្លប់បាត់ស្មារតីដូច្នោះហើយ ក៏នាំគ្នាភៀសផាយក្លាយខ្លួនបាត់ទៅ ។

ឯនាងមទ្រីកាលណាយល់សត្វម្រឹកទាំងបីភៀសផាយក្លាយខ្លួនបាត់អស់ហើយ

ក៏ប្រវេប្រវាចាប់ដង់រែកដាក់លើព្រះអង្សា ។

យាត្រា...ឡើងដល់អាស្រមបរមកុដិក្សត្រីនាងរត់រកកូននាងពុំឃើញទេអើយ

ពេញទាំងដែនដី...ម្តាយឃើញ ទោងដែលម្តាយចងអោយកូនប្រុសស្រី

ហេតុអ្វីក៏បាត់...អាំ...មិនឃើញអ្នកបបួលគ្នាទៅណា ណាស្ងួនអើយស្ងួន ។

ទុក្ខអើយ មទ្រីទាំពីព្រលឹមដល់ព្រលប់ កាយពុំមានឈរឈប់

ខំបេះប្រឡេះផ្លែឈើ យកមកធ្វើ ឥឡូវនេះ តើបាត់កូនសំឡាញ់របស់ខ្ញុំ

ទាំងទ្វេហាទៅណា...បាត់... ។

## ទំនួញកុមារ

ឱះ! ឱអ្នកមេម៉ែមានគុណ បាត់យូរពេកពន់ជាងពីដើម

កូនឈឺខ្លួនណាស់បែកឈាមហើម ដើមទ្រូងស្មើរធ្លាក់ចេញពីគ្នា ។

ជាលីស្រែកថាអាសូរពេក កូនហើយមើលមេឃមិរតាមគ្នា

សន្ទើរមចុះអព្ទ័សព្វទិសា យ៉ាងណាបែបគួរនឹងភ្លៀងផ្គរ ។

កុមារទាំងពីរយំជាទុក្ខ គ្រានោះជូជកមានតែខឹង

ស្ទុះមកសន្ទប់ចាប់ទាញទង់ ហើយវាយយ៉ាងខ្លាំងពុំលែងឡើយ ។

ព្រាហ្មណ៏កន្ត្រាក់ដួលផ្ងារផ្កាប់ ហើយវាយខ្វាប់ៗកុមារស្រែកថា

អាយ យ៉ូយ អាយយ៉ាស ឈឺណាស់ណា ឱះ! ឱមាតាអើយជួយកូនផង ។

កូនឈឺខ្លួនណាស់ពាសពេញខ្នង តាំងពីថ្ងៃត្រង់រហូតថ្ងៃជ្រេ

សង្វៀងជើងណាស់ប្រេះហើមហៀរ បងឈឺខ្លាំងណាស់ណាប្អូនអើយ ។
ព្រាហ្មណ៍ប្រឹងកន្ត្រាក់ឥតមានឈប់ វាយនឹងឈើច្រត់មិនគិតឡើយ
ហើយវាយថែមទៀតឥតមានស្បើយ ឱអ្នកម្តាយអើយសូមជួយកូនផង ។
ទំនួញនាងមទ្រីចូលព្រៃព្រះនាងមទ្រីកែវពន្លក ចូលព្រៃស្វែងរកមូលផលា
បានហើយត្រឡប់វិលយាត្រា ប្រទះសីហាខ្លាកាចក្រៃ ។
ដែលទេពនិមិត្តស្កាត់ចាំផ្លូវ មិនអោយនាងទៅដល់ពីថ្ងៃ
ខ្លាចនាងរត់តាមព្រាហ្មណ៍ចង្រៃ ទាញយកបុត្រថ្លៃដោយស្នេហា ។
លុះដល់អស់ស្តង្គតរាត្រី ទេពតាទាំងបីទ្រង់ករុណា
បើកអោយព្រះនាងយាងយាត្រា ហើយតាមរក្សាមិនអោយហ្មង ។
ព្រះនាងយាងដល់ឯសាលា មិនឃើញបុត្រាទាំងប្អូនបង
ទ្រង់ព្រះកន្សែងក្រៃកន្លង រត់រកដោយដងព្រៃព្រឹក្សា ។
លឺមាត់តាវៅយំក្នុងព្រៃ ហាក់មាត់កូនស្រីនាងក្រឹស្នា
តែងស្រែកម្តាយក្នុងព្រឹក្សា ស្តាប់កាលណាមិនមែនកូនស្រី ។
ព្រះពាយផាយផាត់រសាត់ពពក បក់មកពីទិសខាងនិរតី
ធុំក្លិនក្រអូវផ្កានួនស្រី ស្រមៃហាក់ដូចក្លិនកូនពៅ ។
អ្នកម្តាយឃើញតែទីកន្លែង ដែលកូនធ្លាប់លេងនៅទីកូវ
ឃើញតែស្នាមជើងដែលកូនពៅ នៅកណ្តាលផ្លូវមុខសាលា ។
រឺមួយក្រែងកូនជួបសត្វម្រឹគ ទាំងហ្វូងគគ្រឹកដំរីខ្លា
ខាំពាំកូនទៅជាអាហារ ម្តាយរឹតខ្លោចផ្សាណាកូនអើយ ។
សូម្បីកូនថ្លៃស្រែករកម្តាយ សត្វពាំទៅឆ្ងាយស៊ីកូនហើយ
ឱ្យម្តាយជួយផងកុំកន្តើយ កូនអើយបានស្បើយពីមាត់សត្វ ។

## ទំនួញនាងមទ្រី

សុសាយយណ្តោទេរទន់ទៅ ព្រៃជ្រៅសង្វាត់សត្វផងយំ
ពិរោះដូចភ្លេងលេងរងំ ទុគិមគួរអោយស្រណោះពេក ។
លុះដល់សន្ធ្យាយាមរាត្រី រស្មីចន្ទ័ចែងភ្លឺពាសមេឃ

កុមារយំថ្ងូរអាសូរពេក ឃ្លានស្រេកទឹកដោះពុំមានល្ហែ ។
បបួលបងប្អូនសោកជាទុក្ខ ទល់មុខហើយទូលថាវៀមនែ៎!
ធ្វើម៉េចយើងបានយល់ព្រះម៉ែ ឃើញតែជូជកពុកស្រមាម ។
ប្អូនឃើញជូជកគាត់ហាមាត់ ចង្កេះក្រវាត់ហើយស្ពាយយាម
ឱម្ចាស់បងអើយយើងដើរតាម ក្រែងព្រាហ្មណ៍នាំយើងយកទៅស៊ី ។
បន្ទូលរៀបរាប់សព្វរឿងទុក្ខ ជូជកចងដៃរួមទាំងពីរ
ប្រឹបផ្តោបដើមឈើតាព្រីទ្ធី ម្នាម្នីឡើងដេកលើឈើថ្នាក់ ។